**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សារជូនពរ

## ផ្ញើជូន

## នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី ៧០ នៃទិវាកំណើតកងយោធពលខេមរភូមិន្ទ "៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៣"

**- មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទជាទីស្នេហា !**

ក្នុងឱកាសប្រកបដោយមហានក្ខត្តឫក្សដ៏ឧត្តុង្គឧត្តម នៃទិវាខួបអនុស្សាវរីយ៍លើកទី៧០ កំណើតកងយោធពលខេមរភូមិន្ទ ស្របជាមួយទិវាបុណ្យឯករាជ្យជាតិ "**៩ វិច្ឆិកា ១៩៥៣ - ៩ វិច្ឆិកា ២០២៣**"នេះ តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីអំណរសាទរដ៏តឧបមាក្នុងមនោសញ្ចេតនាគោរពស្រលាញ់ដ៏ជ្រាលជ្រៅ ប្រកបដោយទឹកចិត្តសោមនស្សរីករាយ និងមោទនភាពខ្ពស់ចំពោះនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ។

ខ្ញុំសូមយកឱកាសនេះ ផ្តាំផ្ញើនូវការសាកសួរសុខទុក្ខជាមួយនឹងសេចក្តីនឹករឭកជាអនេក និងសូមប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ បវរមហាប្រសើរជូនចំពោះនាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទ ដែលកំពុងបំពេញភារកិច្ចនៅតាមអង្គភាព, កម្មសិក្សានៅបរទេស និងបំពេញបេសកកម្មរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា កម្លាំងពលំមាំមួន អាយុយឺនយូរ និងសម្រេចបានស្នាដៃថ្មីៗបន្ថែមទៀតក្នុងបេសកកម្មបម្រើជាតិ និងប្រជាជន។ សូមជូនពរចំពោះនាយទាហាន នាយទាហានរង ពលទាហានដែលកំពុងសម្រាកព្យាបាលជំងឺនៅតាមមន្ទីរពេទ្យ និងលំនៅដ្ឋាន សូមមានសុខភាពឆាប់បានជាសះស្បើយ និងអាចវិលត្រឡប់មកបំពេញភារកិច្ចដ៏ឧត្តុងឧត្តមជូនជាតិ មាតុភូមិជាបន្តទៀត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរយ៉ាងស្មោះចំពោះរាល់ស្នាដៃ និងសមិទ្ធផលដ៏ថ្លៃថ្លា មិនអាចកាត់ថ្លៃបាន ដែលកងយោធពលខេមរភូមិន្ទខិតខំប្រឹងប្រែង សម្រេចបាននាពេលកន្លងទៅក្នុងកិច្ចការពារសន្តិភាព ឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីបានយ៉ាងគង់វង្ស ស្ថិតស្ថេរគ្រប់កាលៈទេសៈ ពង្រឹងខឿនការពារជាតិរបស់ប្រជាជនរឹងមាំខ្លាំងក្លា និងធ្វើឱ្យប្រជាជនបានរស់នៅដោយសុខដុមរមនាលើទឹកដីរបស់ខ្លួន និងមានឱកាសពេញលេញសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

**- មេបញ្ជាការ មេបញ្ជាការរង នាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទ!**

ជាមួយនឹងស្នាដៃសមិទ្ធផលលេចធ្លោសម្រេចបានខាងលើ កងយោធពលខេមរភូមិន្ទបានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវយុទ្ធសាស្ត្រ ខ្សែព្រំដែន កសាងភូមិ ឃុំ និងអភិវឌ្ឍន៍សហគមន៍ប្រជាពលរដ្ឋនៅតាមព្រំដែន តាមរយៈការបង្កើត និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្រយោធានៅតាមព្រំដែន សំដៅលើកកម្ពស់ការពង្រឹងយុទ្ធសាស្ត្រការពារព្រំដែនយូរអង្វែង ដែលជាមូលដ្ឋានរឹងមាំមួយ សម្រាប់កិច្ចការពារបូរណភាពទឹកដី និងកសាងព្រំដែនជាតំបន់សន្តិភាព មិត្តភាព សហប្រតិបត្តិការ និងការអភិវឌ្ឍ ព្រមទាំងប្រែក្លាយអតីតសមរភូមិជាតំបន់ផលិតកម្មទីផ្សារ និងទេស-

វិថីហ្សកនីមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៨ អ៊ីមែល៖ generalsec@mod.gov.kh

ចរណ៍។ ជាមួយគ្នានេះ កងយោធពលខេមរភូមិន្ទ បានសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលមូលដ្ឋាន កសាងតំបន់ប្រវត្តិសាស្ត្រយោធា វិមានរំឭកគុណ និងស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ នៅតាមទីតាំងប្រវត្តិសាស្ត្រនានា ដើម្បីចារឹកទុក និងតម្កល់និមិត្តរូប វត្ថុតាងនិងសមិទ្ធផលនានាសម្រាប់ជាថ្នាលបណ្តុះមនសិការ **"កតញ្ញូ សុខដុម និងការចូលរួម"** និងជាមេរៀនសម្រាប់អ្នកជំនាន់ក្រោយចងចាំរៀនសូត្រ គោរពដឹងគុណ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ស្ថាបនិកមគ្គុទ្ទេសក៍ឯក និងប្រតិបត្តិករនយោបាយឈ្នះ ឈ្នះ ដែលនាំមកនូវសន្តិភាព និងការឯកភាពជាតិពេញលេញ ព្រមទាំងចងចាំនូវគុណូបការៈដ៏ថ្លៃថ្លារបស់យុទ្ធជន យុទ្ធនារី ស្នេហាជាតិដែលបានធ្វើពលីកម្មប្រកប ដោយវីរភាពដើម្បីជាតិ មាតុភូមិ។

ទន្ទឹមនេះ កងយោធពលខេមរភូមិន្ទបានសហការជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ រួមចំណែកយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិសុខជាតិ តាមរយៈការអនុវត្តគោលនយោបាយ **"ភូមិ ឃុំ សង្កាត់មានសុវត្ថិភាព"** ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ការកសាងហេដ្ឋារចនាសម្ព័ន្ធ ការការពារធនធានធម្មជាតិ ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការជួយសង្គ្រោះប្រជាជនពេលកើតមានគ្រោះមហន្តរាយផ្សេងៗ ដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ជំងឺឆ្លងរាតត្បាត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងវិស័យការពារជាតិ ដោយផ្អែកលើរដ្ឋធម្មនុញ្ញ ច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដើម្បីពង្រីកសមត្ថភាពការពារជាតិ ពង្រឹងអធិបតេយ្យជាតិ និងលើកកម្ពស់ការចូលរួមសកម្មរបស់កម្ពុជាក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព វិបុលភាពតំបន់ និងពិភពលោក និងបញ្ជូនកងកម្លាំងកម្ពុជាចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាព ក្រោមឆត្រអង្គការសហប្រជាជាតិនៅបណ្តាប្រទេសដែលកំពុងមានវិបត្តិនៅទ្វីបអាហ្វ្រិក និងតំបន់មជ្ឈិមបូព៌ា, ការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩, ការធ្វើម្ចាស់ផ្ទះកិច្ចប្រជុំរដ្ឋមន្ត្រីការពារជាតិអាស៊ាន និង កិច្ចប្រជុំពាក់ព័ន្ធ និងការចូលរួមរៀបចំព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២ ឆ្នាំ២០២៣ ព្រមទាំងព្រឹត្តិការណ៍ជាតិ អន្តរជាតិផ្សេងៗទៀតដំណើរការប្រកបដោយជោគជ័យ និងទទួលបានការកោតសរសើរពីមជ្ឈដ្ឋានជាតិ អន្តរជាតិទៀតផង។

ជាថ្មីម្តងទៀត នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសមិទ្ធផល និងកោតសរសើរដោយស្មោះចំពោះរាល់ស្នាដៃរបស់កងយោធពលខេមរភូមិន្ទសម្រេចបាននាពេលកន្លងមក រហូតមកដល់បច្ចុប្បន្ន និងសូមប្រសិទ្ធពរជ័យជូនចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់ នាយទាហាន នាយទាហានរង និងពលទាហាននៃកងយោធពលខេមរភូមិន្ទកំពុងឈរជើងនៅតាមព្រំដែនទឹក-គោក, បំពេញកម្មសិក្សានៅបរទេស, បំពេញបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងអតីតយុទ្ធជនទាំងអស់ សូមទទួលបានជោគជ័យ សិរីមង្គល វិបុលសុខ ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ១១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**